

# និយាយសួស្ដីទៅកាន់ហាលីម !



**យើងអាចមានសន្ដានចិត្តល្អ**

« យើងម្នាក់ៗអាចអភិវឌ្ឍភាពរាប់អានគ្នាជាបងប្អូននៅផ្ទះ សាលារៀន កន្លែងធ្វើការ ឬនៅកន្លែងលេងកម្សាន្ត » ។

ប្រធាន រ័សុល អិម ណិលសុន « These . . . Were Our Examples » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩១ ទំព័រ ៦២ ។

**ដោយ ខាធី ខាធី វើដ័យ**
ផ្អែកទៅលើដំណើររឿងពិត

*« អ្នករាល់គ្នាបានទទួលទទេ ត្រូវឲ្យទទេដែរ » ( ម៉ាថាយ ១០:៨ ) ។*

នៅសាលារៀននាព្រឹកនោះ ម៉ាគើសបានសង្កេតឃើញក្មេងប្រុសចំណូលថ្មីម្នាក់ដើរចូលមកក្នុងថ្នាក់រៀន ។

អ្នកគ្រូប៉ែកឃើរបាននិយាយពេលសិស្សគ្រប់គ្នាស្ងាត់ស្ងៀមថា « អរុណសួស្ដីប្អូនៗ ។ នេះគឺហាលីម ។ គាត់ជាអ្នកចំណូលថ្មីនៅសាលារៀនយើង ។ តាមពិតទៅ គាត់ជាអ្នកចំណូលថ្មីមកក្នុងប្រទេសយើង ។

ហាលីមបានឱនមុខមើលកម្រាលឥដ្ឋពេលគាត់និយាយថាសួស្ដី ។ ម៉ាគើសបានគិតថា សំឡេងរបស់គាត់ដូចជាមានសំឡេងខុសប្លែក ។ អ្នកគ្រូប៉ែកឃើរបន្តនិយាយទៀត ។

« ពួកយើងរីករាយដែលគាត់នៅទីនោះ ហើយគាត់នឹងក្លាយជាសិស្សក្នុងថ្នាក់យើង ។ អ្នកគ្រូសង្ឃឹមថា យើងទាំងអស់គ្នាជួយឲ្យគាត់មានអារម្មណ៍កក់ក្ដៅ » ។

ពេលអ្នកគ្រូប៉ែកឃើរបង្ហាញតុអង្គុយឲ្យហាលីម ម៉ាគើសបានគិតអំពីការភ័យខ្លាចរបស់គាត់ ប្រសិនបើគាត់បានប្ដូរទៅប្រទេសថ្មីមួយ និងសាលារៀនថ្មីមួយ ។

បន្ទាប់ពីម៉ោងញ៉ាំអាហារសម្រន់រួច អ្នកគ្រូប៉ែកឃើរបានប្រាប់សិស្សគ្រប់គ្នាថា គាត់មានអ្វីមួយភ្ញាក់ផ្អើលបង្ហាញពួកគេ ។ ម៉ាគើសបានអង្គុយយ៉ាងត្រង់ខ្លួន ដើម្បីគាត់អាចមើលឃើញអ្វីដែលអ្នកគ្រូដកចេញពីកាបូបរបស់គាត់ ។ វាជាធុងតូចៗ ។ គាត់បានចាប់ផ្ដើមហុចធុងនោះតៗគ្នាទៅសិស្សក្នុងថ្នាក់ ។

គាត់បាននិយាយពេលគាត់ហុចធុងពណ៌លឿងឲ្យម៉ាគើស « យើងម្នាក់ៗមានធុងនៃក្ដីស្រឡាញ់មួយនៅក្នុងចិត្តយើងម្នាក់ៗ ។ មនុស្សបំពេញធុងរបស់យើងពេលពួកគេធ្វើរឿងល្អៗដល់យើង ។ ហើយយើងអាចបំពេញធុងរបស់មនុស្សដទៃតាមរយៈការធ្វើល្អចំពោះពួកគេដែរ ។ ឧទាហរណ៍ ពេលម្ដាយប្អូនឱបប្អូន គាត់កំពុងបំពេញធុងរបស់ប្អូន ។ ពេលប្អូនៗនិយាយអ្វីមួយល្អៗទៅកាន់នរណាម្នាក់ នោះប្អូនៗកំពុងបំពេញធុងរបស់ពួកគេ ។

ម៉ាគើសបានមើលទៅមិត្តជិតស្និទរបស់គាត់ឈ្មោះកាលីប ។ គាត់ក៏បានធុងពណ៌លឿងផងដែរ !

អ្នកគ្រូប៉ែកឃើរបាននិយាយថា « សប្ដាហ៍នេះ យើងនឹងទុកធុងទាំងនេះនៅលើតុរបស់យើង ដូច្នេះយើងអាចសរសេរកំណត់ចំណាំល្អៗសម្រាប់គ្នាទៅវិញទៅមក » ។ គាត់បានមូរក្រដាសតូចមួយ ហើយទម្លាក់វាចូលក្នុងធុងនោះ ។ « ហើយវានឹងជួយយើងឲ្យចងចាំពីធុងនៃក្ដីស្រឡាញ់ ដែលមនុស្សគ្រប់គ្នាមាននៅក្នុងធុងនោះ ។ យើងចង់មានសន្ដានចិត្តល្អ ដើម្បីឲ្យយើងធ្វើជាអ្នកបំពេញធុងនោះ ។

ម៉ាគើសបានទាញយកក្រដាសមួយសន្លឹកមក ហើយបានគិតអំពីអ្វីៗដែលគាត់អាចសរសេរទៅកាន់កាលីប ដូចជាថាគាត់ពូកែលេងកីឡា ។ ប៉ុន្តែក្រោយមកគាត់បានមើលទៅហាលីម ។ ស្មារបស់គាត់ហាក់ដូចកោងដោយកើតទុក្ខ ។

ម៉ាគើសឆ្ងល់ថា តើហាលីមមានកល្យាណមិត្តម្នាក់ នៅកន្លែងដែលគាត់ធ្លាប់រស់នៅដែរឬទេ ។ វាប្រហែលជាលំបាកណាស់ដើម្បីនិយាយលាពួកគេ ហើយភ័យខ្លាចចំពោះការប្ដូរទៅរស់នៅឆ្ងាយ ។

ម៉ាគើសបានមើលទៅក្រដាសសៀវភៅទទេនៅលើតុរបស់គាត់ ។ គាត់មានគំនិតមួយ បន្ទាប់មកគាត់បានសរសេរថា

« ជូនចំពោះហាលីម

សូមស្វាគមន៍មកសាលារៀនរបស់យើង ។ ប្រសិនបើឯងចង់ យើងអាចលេងជាមួយគ្នាពេលម៉ោងចេញលេង ។ ខ្ញុំនឹងធ្វើជាមិត្តភក្ដិរបស់ឯង ។ ហើយខ្ញុំគិតថា កាលីបនឹងធ្វើជាមិត្តរបស់ឯងដែរ ។

ពីខ្ញុំ ម៉ាគើស » ។

បន្ទាប់មកគាត់បានមូរក្រដាសនោះដោយប្រុងប្រយ័ត្ន ហើយទម្លាក់វាចូលក្នុងធុងរបស់ហាលីម ។ ហាលីមបានញញឹម ។ ម៉ាគើសបានទទួលអារម្មណ៍កក់ក្ដៅ និងរីករាយក្នុងចិត្ត ។ គាត់ចូលចិត្តធ្វើជាអ្នកបំពេញធុង ! ●

*អ្នកនិពន្ធរស់នៅរដ្ឋ អៃដាហូ ស.រ.អា ។*

